**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**កិច្ចព្រមព្រៀង**

**រវាង**

**រោងចក្រ អរិន មេនូហ្វេកឆឺរីង (ខ្មែរ)**

**ជាមួយតំណាងប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋានប្រចាំ**

**រោងចក្រ អរិន មេនូហ្វេកឆឺរីង (ខ្មែរ)**

**ស្តីអំពីការព្យួរកិច្ចសន្យាការងារ**

នៅថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០២៤ វេលាម៉ោង០៩ និង ០០នាទី ព្រឹក នៅក្នុងរោងចក្រ **អរិន មេនូហ្វេកឆឺរីង(ខ្មែរ)** មានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន តំណាងកម្មករ និយោជិត និងប្រធានក្រុម ។ នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករ និយោជិតទាំងអស់ស្តីពីស្ថានភាព បច្ចុប្បន្ននៃក្រុមហ៊ុនដែលខ្វះអ្នកបញ្ជាទិញដែល បណ្តាលឱ្យផ្នែកខ្លះផ្អាកដំណើរការសង្វាក់ផលិតកម្ម។ ហេតុដូចនេះក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ៦៩៦នាក់ (ស្រី ៦២១នាក់) ក្នុងចំណោមចំនួនកម្មករនិយោជិតសរុប ១,៦២៧ នាក់ រយៈពេល ០២ខែ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៥ រហូតដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥ ។ ហើយក្នុងអំឡុងពេលព្យួរការងារនេះ កម្មករនិយោជិតឯកភាពទទួលយកនូវការផ្តល់ជូនរបស់ក្រុមហ៊ុនក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងាររយៈពេល ៥៩ថ្ងៃ កម្មករនិយោជិតព្រមទទួលប្រាក់ឧបត្ថម្ភពីក្រុមហ៊ុនចំនួន ៦០ដុល្លារអាមេរិក។

- កាលបរិច្ឆេទបើកប្រាក់ឧបត្ថម្ភព្យួរកិច្ចសន្យាការងារនេះបើកលើកទី ០១ នៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០២៥ លើកទី០២ នៅថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២៥ ។

អង្គប្រជុំបានបញ្ចប់វេលាម៉ោង ១១ និង ០០នាទីព្រឹក នាថ្ងៃខែឆ្នាំដដែល ដោយភាគីទាំងសងខាងមានភាពស្និទ្ធស្នាល និងការឯកភាពយល់គ្នាក្រោមស្មារតីទទួលខុសត្រូវ និង សហការគ្នាយ៉ាងរលូន ។

ថ្ងៃសុក្រ៦កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ២៥៦៨

កំចាយមារ.ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០២៤

**ជ-តំណាងក្រុមហ៊ុន**

**ពេជ្រ សូផាត**

**ស្នាមមេដៃតំណាងកម្មករ និយោជិត**

**កិច្ចព្រមព្រៀង**

**រវាង**

**ក្រុមហ៊ុន អរិន មេនូហ្វេកឆឺរីង (ខ្មែរ)**

**ជាមួយតំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំក្រុមហ៊ុន**

ខ៉ុន សាក

ក្ប ឧទ្ធ

កុង សាម៉ុល

ពៅម ភិន

ម៉ុង ទឹកវ

ឃុន ចិតរតិយ

ស៊ុម ស្រីហាខ

ឃុន ម៉ិច

ប៉ុម ប្រិ៍

ណែម សារ៉

កុលណ វិសិទ្ធ

ស ស៊ីភួ

សុន សាម៉ុម

រី សីហា

ពៅស្រី កញ្ញា

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
អរិន ម៉េនូហ្វេកឃើរីង (ខ្មែរ)
ORANGE MANUFACTURING (KHMER) Co., Ltd.
KINGDOM OF CAMBODIA